**LOWELL PUBLIC SCHOOLS**
Henry J. Mroz Central Administration Offices
155 Merrimack Street
Lowell, MA 01852

ថ្ងៃទី 09 ខែ តុលា ឆ្នាំ 2020

គោរពជូនគ្រួសារនៃសង្កាត់សាលា Lowell Public Schools ៖

កាលពីថ្ងៃពុធ យើងបានចែករំលែកជាមួយលោកអ្នកនូវតួលេខថ្មីបំផុតពីរបាយការណ៍ប្រចាំសប្តាហ៍ដែលបានមកពីគេហទំព័រស្តីពីជំងឺ COVID-19 របស់រដ្ឋ និងរបៀបដែលចំនួនករណីជំងឺ COVID-19 នៅទីនេះក្នុងក្រុង Lowell បន្តកើនឡើងយ៉ាងដូចម្តេចរួចហើយ។ យោងតាមបច្ចុប្បន្នភាពស្តីពីជំងឺ COVID-19 កាលថ្ងៃពុធនោះបានឲ្យដឹងថា អាត្រាករណីប្រចាំថ្ងៃជាមធ្យមក្នុងចំណោមអ្នកស្រុក 100,000 នាក់ក្នុងក្រុង Lowell គឺមានចំនួន 16.3 នាក់ ដែលកើនពីចំនួន 10.9 នាក់កាលពីសប្តាហ៍មុន។ អាត្រានេះបានដាក់ក្រុង Lowell នៅក្នុងកូដសម្គាល់ពណ៌ “ក្រហម” ឬ ក្នុងប្រភេទដែលមាន ហានិភ័យខ្ពស់ សម្រាប់សប្តាហ៍ទីពីរជាប់ៗគ្នានេះ។ អាត្រាភាគរយវិជ្ជមាន របស់យើង (ភាគរយនៃការធ្វើតេស្តដែលរកឃើញថាវិជ្ជមានជំងឺ COVID-19 នៅទីនេះក្នុងក្រុង Lowell) ក៏បានកើនឡើងដល់ចំនួន 3.57% ផងដែរ ដែលកើនពីចំនួន 2.71% កាលពីសប្តាហ៍មុន។

ក្រសួងអប់រំបឋមសិក្សានិងមធ្យមសិក្សា បានណែនាំឲ្យសង្កាត់សាលាទាំងឡាយបន្តត្រួតពិនិត្យមើលឡើងវិញនូវទិន្នន័យចំនួនបីសប្តាហ៍ជាប់ៗគ្នាពីរបាយការណ៍សុខភាពសាធារណៈស្តីពីជំងឺ COVID-19 ប្រចាំសប្តាហ៍របស់រដ្ឋ Massachusetts ។ កាលពីថ្ងៃទី 08 ខែ តុលា ឆ្នាំ 2020 ក្រុមប្រឹក្សាសុខាភិបាលនៃក្រុង Lowell បានផ្តល់ជូនយើងនូវការណែនាំដែលថា រយៈពេលបីសប្តាហ៍នៅក្នុងកូដសម្គាល់ពណ៌ក្រហមគឺជាកម្រិតកំណត់សមល្មមដើម្បីគាំទ្រការរៀនសូត្រពីចម្ងាយហើយ ។ ហេតុនេះហើយ យើងចង់ផ្តល់ការជូនដំណឹងដល់គ្រួសារឲ្យបានច្រើនតាមដែលអាចធ្វើបានដែលថា **ប្រសិនក្រុង** Lowell **ត្រូវបានគេដាក់កូដសម្គាល់ពណ៌ ក្រហម នៅសប្តាហ៍ក្រោយម្តងទៀតនោះ សង្កាត់នេះនឹងត្រូវប្តូរទៅកាន់មធ្យោបាយរៀនសូត្រពីចម្ងាយពេញលេញវិញ ដែលនឹងចាប់ផ្តើមពេលសាលារៀនចាប់ផ្តើមនៅថ្ងៃច័ន្ទ ទី 19 ខែ តុលា ឆ្នាំ 2020 ។** យើងនឹងបន្តសិក្សាពីករណីអាចលើកលែងបានផ្សេងៗសម្រាប់កម្មវិធីពិសេសតូចៗ និងធ្វើការទំនាក់ទំនងជាមួយលោកអ្នកពីករណីលើកលែងដែលអាចកើតមានឡើងណាមួយនៅសប្តាហ៍ក្រោយ បន្ទាប់ពីយើងពិនិត្យមើលឡើងវិញនូវទិន្នន័យជំងឺ COVID-19 ដែលបានធ្វើបច្ចុប្បន្នភាពហើយ។

ចាប់តាំងពីការចាប់ផ្តើមការរៀនដោយផ្ទាល់មក យើងបានមានហេតុការណ៍កើតមានជំងឺ COVID-19 តែពីរបីករណីប៉ុណ្ណោះនៅក្នុងសាលារៀនរបស់យើង ប៉ុន្តែនេះជាវិធានការសុខភាពបង្ការទុកមុន ដោយសារកម្រិតបច្ចុប្បន្ននៃការរីករាលដាលក្នុងសហគមន៍នៃជំងឺ COVID-19 នៅក្នុងក្រុង Lowell ។ យើងយល់ពីផលប៉ះពាល់ ដែលសេចក្តីសម្រេចដ៏ពិបាកនេះមានលើសិស្ស និង គ្រួសាររបស់ពួកគេ ដូច្នេះលិខិតនេះគឺមានបំណងផ្តល់ការជូនដំណឹងឲ្យបានច្រើនតាមដែលអាចធ្វើបាននៅមុនពេលនៃការចេញផ្សាយទិន្នន័យស្តីពីជំងឺ COVID-19 នៅសប្តាហ៍ក្រោយ។ សម្រាប់ពេលនេះ យើងមានទិន្នន័យស្តីពីជំងឺ COVID-19 តែពីរសប្តាហ៍ប៉ុណ្ណោះដែលបានដាក់ដាក់កូដសម្គាល់ក្រុង Lowell ជាពណ៌ ក្រហម ដូច្នេះ **ការរៀនដោយផ្ទាល់នឹងបន្តនៅសប្តាហ៍ក្រោយតាមការគ្រោងទុក។**

យើងនឹងទាក់ទងលោកអ្នកនៅព្រឹកថ្ងៃព្រហស្បតិ៍សប្តាហ៍ក្រោយព្រមជាមួយនឹងព័ត៌មានបន្ថែមទៀត បន្ទាប់ពីយើងបានពិនិត្យមើលឡើងវិញនូវទិន្នន័យថ្មីបំផុត ដែលបានផ្តល់ជូនដោយក្រសួងសុខាភិបាល និង របាយការណ៍សុខភាពសាធារណៈស្តីពីជំងឺ COVID-19 ប្រចាំសប្តាហ៍របស់រដ្ឋ Massachusetts ។

យើងសូមថ្លែងអំណរគុណចំពោះការបន្តភាពជាដៃគូនិងភាពអាចបត់បែនបានរបស់លោកអ្នក ស្របពេលដែលយើងកំពុងប្រឹងប្រែងដើម្បីរក្សាសុវត្ថិភាពសម្រាប់សិស្ស គ្រួសារ និង បុគ្គលិករបស់យើង នៅអំឡុងពេលដ៏ពិបាកនិងមិនច្បាស់លាស់ទាំងនេះ។

ដោយក្តីស្មោះស្ម័គ្រ,

John J. Leahy
អភិបាលក្រុង

Dr. Joel D. Boyd
អ្នកមើលការខុសត្រូវសង្កាត់សាលា